ការិយាល័យកណ្តាល

# សេចក្តីជូនដំណឹង

## ស្តីពី

## លទ្ធផលនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៤ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិក និងសាធារណជន មេត្តាទទួលជ្រាបថា កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៤ តាមរយៈ **Video Con-Call** របស់ធនាគារ អេស៊ីលីដា នៅ **ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤** នៅម៉ោង**១៤:០០នាទី ដល់ម៉ោង ១៦:១០នាទី** មានកូរ៉ុមចំនួន **៨៤,៦៥**ភាគរយ និងភាគហ៊ុនិកចូលរួមចំនួន **១៧៧**នាក់ ស្មើនឹង **៣៦៦.៦៥៣.៣១៩**ភាគហ៊ុន។

ភាគហ៊ុនិកបានពិនិត្យ ពិភាក្សា និងអនុម័តដូចខាងក្រោម៖

១. អនុម័តការបែងចែកភាគលាភជាសាច់ប្រាក់ចំនួន**១០ភាគរយ** នៃប្រាក់ចំណេញក្នុងឆ្នាំ២០២៣ ដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ អេស៊ីលីដា ចំនួន**៦០៨.៥០៥.១៨៩.០០០រៀល** ស្មើនឹង**៦០.៨៥០.៥២៤.៣២៧,៦៣រៀល** ក្នុងអត្រា **១៤០,៤៧៩៥**រៀល ក្នុង១ភាគហ៊ុន និងរក្សាប្រាក់ចំណេញនៅសល់ក្នុងខ្ទង់ប្រាក់ចំណេញរក្សាទុករបស់ធនាគារ អេស៊ីលីដា។
***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៨,៨៥ ភាគរយ។***

២. អនុម័តការធ្វើវិសោធនកម្ម មាត្រា៨ និងឧបសម្ព័ន្ធ៣ នៃលក្ខន្តិកៈ ធនាគារ អេស៊ីលីដា។
***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៨,៩៥ ភាគរយ។***

៣. អនុម័តកម្រៃសេវា សម្រាប់ក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ស្របតាមអត្រាអតិផរណាប្រចាំឆ្នាំ២០២៣ ចំនួន ២,១ភាគរយ។
***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,១០ ភាគរយ។***

៤. អនុម័តការដំឡើងប្រាក់បៀវត្សជូនប្រធានក្រុមប្រឹក្សាភិបាលដូចខាងក្រោម៖
- ដំឡើងប្រាក់បៀវត្សជូន **លោក ឆាយ សឿន** ប្រធានក្រុមប្រឹក្សាភិបាល ដោយទទួលបានចំណាត់ថ្នាក់ “A+” ដែលមានប្រសិទ្ធភាពអនុវត្តប្រតិសកម្ម ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤។
- បូកបន្ថែមអត្រាអតិផរណាប្រចាំឆ្នាំ២០២៣ ចំនួន ២,១% (ពីរក្បៀសមួយភាគរយ) លើប្រាក់បៀវត្សរបស់ប្រធានក្រុមប្រឹក្សាភិបាល ដែលមានប្រសិទ្ធភាពអនុវត្តប្រតិសកម្ម ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៨,៩២ ភាគរយ។***

៥. អនុម័តលើការតែងតាំង **លោក ឆាយ សឿន** ជាអភិបាល នៅធនាគារ អេស៊ីលីដា ចាប់ពីថ្ងៃចូលនិវត្តន៍ អាយុ ៧០ឆ្នាំ នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។
***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,១៤ ភាគរយ។***

៦. អនុម័តការតែងតាំង **លោក Pieter Kooi** ជាអភិបាលឯករាជ្យ ធនាគារ អេស៊ីលីដា សម្រាប់អាណត្តិថ្មី រយៈពេល៣ឆ្នាំបន្ថែមទៀត។
***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,១០ ភាគរយ។***

៧. អនុម័តការតែងតាំង **លោកស្រី ភូរិ រតនា** ជាអភិបាលឯករាជ្យ ធនាគារ អេស៊ីលីដា សម្រាប់អាណត្តិថ្មី រយៈពេល៣ឆ្នាំបន្ថែមទៀត។
***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,០៩ ភាគរយ។***

៨. អនុម័តការតែងតាំង **លោក Stéphane MANGIAVACCA** មកពីស្ថាប័ន COFIBRED ជាអភិបាលធនាគារ អេស៊ីលីដា សម្រាប់អាណត្តិថ្មី រយៈពេល ៣ឆ្នាំបន្ថែមទៀត។
***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,១៣ ភាគរយ។***

ចុះបញ្ជីក្រោមលេខ
Registration No. 00003077
អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

៩. អនុម័តការតែងតាំង **បណ្ឌិត Albertus BRUGGINK** មកពីស្ថាប័ន ORIX ជាអភិបាលធនាគារ អេស៊ីលីដា សម្រាប់អាណត្តិថ្មី រយៈពេល៣ ឆ្នាំបន្ថែមទៀត។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,១២ ភាគរយ។***

១០. អនុម័តកាលបរិច្ឆេទកំណត់ទុកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤ សម្រាប់កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិក ដែលត្រូវទទួលបានភាគលាភ។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៩,១៧ ភាគរយ។***

ថ្ងៃព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**